# អនុក្រឹត្យលេខ ៣៦ អនក្រ. បក
## ស្តីពីការគ្រប់គ្រងកម្មវិធីវិនិយោគសាធារណៈ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញបានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញបានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញបានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតប្រព័ន្ធជាតិសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ ការរៀបចំ ការអនុវត្តន៏ ការតាមដានត្រួតពិនិត្យនិងការវាយតំលៃការអនុវត្តន៏កម្មវិធីវិនិយោគសាធារណៈរបស់រដ្ឋាភិបាលកម្ពុជា ។

## ជំពូកទី ២
## នីតិវិធីនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ

**មាត្រា ២ .-**

កម្មវិធីវិនិយោគសាធារណៈ ជាកម្មវិធីវិនិយោគរយៈពេលបីឆ្នាំដោយធ្វើការកែលំអជារៀងរាល់ឆ្នាំ ។

**មាត្រា ៣ .-**

គំរោងកម្មវិធីវិនិយោគសាធារណៈសំរាប់វិស័យរបស់ក្រសួង ស្ថាប័នត្រូវកសាងឡើងតាមខ្លឹមសារនិង ស្មារតីនៃសារាចរអន្តរស្ថាប័នប្រចាំឆ្នាំ រវាងក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ស្តីពីការកសាងគំរោងកម្មវិធីវិនិយោគសាធារណៈ ដោយមានការរួមយោបល់ពីក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ។

www.pheakdeylaw.com

មាត្រា៤ .-

ការពិនិត្យ ការវាយតំលៃ ការកំណត់អាទិភាពរបស់គំរោងទាំងអស់ និងការចងក្រងជាសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ត្រូវប្រើប្រាស់ដោយតម្លាភាពនូវលក្ខណៈវិនិច្ឆ័យដែលបានកំណត់ និងចំណាត់ថ្នាក់អាទិភាពរបស់គំរោងនីមួយៗ ។

មាត្រា៥ .-

ការរៀបចំកម្មវិធីយោគសាធារណៈ ត្រូវផ្អែកលើមូលដ្ឋាននៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច រយៈពេល៥ឆ្នាំ លើកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល លើសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច លើការគាំរបស់រូបរាងគោលដៅនៃការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាមួយនឹងទស្សនៈរបស់ភាគីម្ចាស់ជំនួយ និងលទ្ធភាពស្រូបយករបស់ភាគីកម្ពុជា ។

មាត្រា៦ .-

សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិមួយៗ ។

## ជំពូក ទី ៣

## សមត្ថកិច្ចក្នុងការកសាងនិងអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈ

មាត្រា៧ .-

ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរអន្តរស្ថាប័ន ដើម្បីណែនាំបណ្តាក្រសួងស្ថាប័នឲ្យកសាងគំរោងកម្មវិធីវិនិយោគសាធារណៈរបស់វិស័យដែលខ្លួនគ្រប់គ្រង តាមកាលបរិច្ឆេទដែលបានកំណត់ ។

មាត្រា៨ .-

បណ្តាក្រសួង-ស្ថាប័ន ត្រូវកសាងគំរោងកម្មវិធីវិនិយោគសាធារណៈ ក្នុងវិស័យដែលខ្លួនគ្រប់គ្រង ដោយយោងតាមសារាចរអន្តរស្ថាប័នដូចក្នុងមាត្រា ៧ ហើយផ្ញើជូនទៅក្រសួងផែនការ ដោយមានហត្ថលេខាបញ្ជាក់របស់ រដ្ឋមន្ត្រីសាមីក្រសួង ឬប្រធានសាមីស្ថាប័ន ។

មាត្រា៩ .-

បណ្តាក្រសួង-ស្ថាប័ន ត្រូវខិតខំអនុវត្តឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពនូវគំរោង កម្មវិធីវិនិយោគសាធារណៈដែលគណៈរដ្ឋមន្ត្រីបានអនុម័ត ។ ក្នុងករណីមានការកែប្រែ ឬមានគំរោង ថ្មីបន្ថែម ត្រូវសុំទិដ្ឋាការឯកភាពជាមុនពីក្រសួងផែនការ ។

**មាត្រា ១០ .-**

បណ្ដាក្រសួងស្ថាប័ន ត្រូវអនុវត្តនីតិវិធីរៀបចំផែនការ និងអនុវត្តគម្រោងកម្មវិធីវិនិយោគសាធារណៈរបស់ខ្លួន ដោយមានការអញ្ជើញតំណាងពីក្រសួង-ស្ថាប័នពាក់ព័ន្ធ មកចូលរួមនៅពេលធ្វើការរៀបចំ ។

**មាត្រា ១១ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ដល់កញ្ចប់ថវិកាជំពូក ៥០ ផ្ដល់សេចក្ដីរាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងគម្រោងកម្មវិធីវិនិយោគសាធារណៈរបស់ខ្លួនជារៀងរាល់ឆ្នាំ ទៅក្រសួងផែនការ ដើម្បីឲ្យក្រសួងផែនការធ្វើការពិនិត្យវាយតម្លៃ កំណត់អាទិភាពគម្រោង និងធ្វើវិភាជន៍ទុនវិនិយោគសាធារណៈ។

**មាត្រា ១២ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ " ថវិកាជាតិនឹងធ្វើបរិញ្ញាប្បទានទុនវិនិយោគ និងទុនបដិភាគ ដល់បណ្ដាគម្រោងនិងកម្មវិធីទាំងឡាយណា ដែលត្រូវបានស្នើជាផ្លូវការតាមបែបបទ និងនីតិវិធីនៃកម្មវិធីវិនិយោគសាធារណៈ និងដែលត្រូវបានក្រសួងផែនការដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈរួចហើយ" ។

**មាត្រា ១៣ .-**

ក្រសួងផែនការ ត្រូវធ្វើការចងក្រងលក្ខណៈវិនិច្ឆ័យដែលត្រូវប្រើក្នុងការកំណត់អាទិភាពកម្មវិធី វិនិយោគសាធារណៈ ចន្លោះពិន្ទុ និងមេគុណ ដែលត្រូវផ្ដល់ក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ ពិន្ទុមធ្យមសរុបរបស់ គម្រោងនីមួយៗ ចំណាត់ថ្នាក់ អាទិភាពតាមពិន្ទុមធ្យមសរុបរបស់គម្រោងនីមួយៗ ។

**មាត្រា ១៤ .-**

ក្រសួងផែនការ ត្រូវយកគម្រោងកម្មវិធីវិនិយោគសាធារណៈដូចក្នុងមាត្រា ៩ ផងព័ត៌មានដូចក្នុងមាត្រា ១១ និងដំណើរការធ្វើចំណាត់ថ្នាក់អាទិភាពគម្រោងកម្មវិធីវិនិយោគសាធារណៈដូចក្នុងមាត្រា ១៣ មក ធ្វើការពិនិត្យ វាយតម្លៃកំណត់អាទិភាពរបស់គម្រោងទាំងអស់ មកចងក្រងសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ និងធ្វើបញ្ជីសង្ខេបមួយស្ដីពីបណ្ដាគម្រោងកំពុងដំណើរការ គម្រោងមានកិច្ចសន្យាផ្ដល់ទុនរួចហើយ និងគម្រោងមាន អាទិភាពខ្ពស់នៃកម្មវិធីវិនិយោគសាធារណៈ ក្នុងឆ្នាំសារពើពន្ធ ។

**មាត្រា ១៥ .-**

ក្រសួងផែនការ ត្រូវផ្ញើរសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈទៅគ្រប់ក្រសួង-ស្ថាប័ន និងដឹកនាំការប្រជុំអន្តរក្រសួង-ស្ថាប័ន ដើម្បីធ្វើការកែតម្រូវសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈនោះ

www.pheakdeylaw.com

រួចផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើថវិកាកម្ម និងបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយនិងផ្ញើទៅគណៈរដ្ឋមន្ត្រីសុំការ ពិនិត្យ អនុម័ត។

មាត្រា ១៦

ក្រសួងផែនការ ត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការចំពោះគំរោងវិនិយោគសាធារណៈថ្មី ឬគំរោងវិនិយោគសាធារណៈដែលត្រូវកែប្រែ របស់ក្រសួង-ស្ថាប័ន ហើយនិងចូលរួមវាយតំលៃការដេញថ្លៃអនុវត្តគំរោង វិនិយោគសាធារណៈ របស់បណ្តាក្រសួង-ស្ថាប័ន។

មាត្រា ១៧ .-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវយកកម្មវិធីវិនិយោគសាធារណៈដែលគណៈរដ្ឋមន្ត្រីបានអនុម័តទៅធ្វើការអំពាវនាវ កៀងគររកជំនួយ មកគាំទ្រដល់ការអនុវត្តន៍រាល់គំរោងវិនិយោគសាធារណៈដែលមិនទាន់ មានទុនអនុវត្ត និងផ្តល់ពត៌មានអំពីលទ្ធផលនៃការកៀងគររកជំនួយមកគាំទ្រ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ។

## ជំពូក ទី ៤

## អំពីការពិនិត្យតាមដាននិងវាយតំលៃ

## លទ្ធផលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈ

មាត្រា ១៨ .-

ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបង្កើតក្រុមការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រចាំក្រសួងស្ថាប័នរបស់ខ្លួនដើម្បីធ្វើការពិនិត្យនិងវាយតម្លៃពីលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តន៍គំរោងកម្មវិធិវិនិយោគ សាធារណៈក្នុងវិស័យខ្លួនគ្រប់គ្រង។

មាត្រា ១៩ .-

ក្រសួង-ស្ថាប័នទាំងអស់ ដែលជាម្ចាស់គំរោងកម្មវិធីវិនិយោគសាធារណៈ ត្រូវរាយការណ៍ដោយទៀងទាត់ក្នុង ៣ខែម្តង នាចុងខែមិថុនា ចុងខែកញ្ញា និងចុងខែធ្នូ អំពីលទ្ធផលនិង ស្ថានភាពនៃការអនុវត្តន៍គំរោងកម្មវិធីវិនិយោគសាធារណៈក្នុងវិស័យដែលខ្លួនទទួលខុសត្រូវ ទៅក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

មាត្រា ២០ .-

ក្រសួង-ស្ថាប័នទាំងអស់ដែលជាម្ចាស់គំរោងកម្មវិធីវិនិយោគសាធារណៈ ត្រូវទទួលយកសំណើ និងបង្កលក្ខណៈងាយស្រួលឲ្យក្រសួង-ស្ថាប័នមានសមត្ថកិច្ច ធ្វើការតាមដានពិនិត្យ និងវាយតំលៃអំពីលទ្ធផលនៃ ការអនុវត្តន៍គំរោងកម្មវិធីសាធារណៈក្នុងវិស័យខ្លួនគ្រប់គ្រង ។

www.pheakdeylaw.com

មាត្រា ២១ .-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើសវនកម្មលើការប្រើប្រាស់ថវិកាក្នុងការអនុវត្តន៍ផែនការ កម្មវិធីវិនិយោគសាធារណៈ ក្នុងវិស័យរបស់បណ្ដាក្រសួង-ស្ថាប័ន តាមច្បាប់គ្រប់គ្រងថវិការដ្ឋ ។

មាត្រា ២២ .-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវធ្វើការតាមដានពិនិត្យ និងវាយតំលៃអំពីល្បឿន និងមូលហេតុ ជះឥទ្ធិពលលើល្បឿននៃការអនុវត្តន៍ផែនការកម្មវិធីវិនិយោគសាធារណៈ ដែលបានប្រើប្រាស់ថវិកាជំនួយ មកពីក្រៅប្រទេស ក្នុងវិស័យដែលបណ្ដាក្រសួង-ស្ថាប័នគ្រប់គ្រង ។

មាត្រា ២៣ .-

ក្រសួងផែនការ ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃអំពីផលប៉ះពាល់ និងលទ្ធផល នៃការអនុវត្តន៍ផែនការកម្មវិធីវិនិយោគសាធារណៈ ទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការកែលំអ ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងវិស័យរបស់បណ្ដាក្រសួងស្ថាប័នគ្រប់គ្រង។

មាត្រា ២៤ .-

ករណីឃើញមានភាពមិនប្រក្រតីក្នុងការអនុវត្តន៍ផែនការកម្មវិធីវិនិយោគសាធារណៈណាមួយ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសហការគ្នាពិគ្រោះ យោបល់រកដំណោះស្រាយជាបន្ទាន់ជាមួយក្រសួង - ស្ថាប័នដែលគ្រប់គ្រងផែនការកម្មវិធីវិនិយោគសាធារណៈនោះ ។

## ជំពូក ទី ៥

## ប្រតិទិនកសាងកម្មវិធីវិនិយោគសាធារណៈ

មាត្រា២៥ .-

ក្នុងខែមិថុនា ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរណ៍អន្តរស្ថាប័ន ដើម្បីណែនាំបណ្ដាក្រសួង-ស្ថាប័នឲ្យកសាងផែនការកម្មវិធីវិនិយោគសាធារណៈ ក្នុងវិស័យដែលខ្លួនគ្រប់ គ្រងដោយផ្អែកលើមូលដ្ឋាននៃការវាយតំលៃពីលទ្ធផលនៃការអនុវត្តន៍ផែនការ កម្មវិធីវិនិយោគសាធារណៈ រៀងឆ្នាំកន្លងមក ។

មាត្រា ២៦ .-

ក្នុងខែកក្កដា បណ្ដាក្រសួង ស្ថាប័ន ត្រូវផ្ញើរផែនការកម្មវិធីវិនិយោគសាធារណៈទាំងអស់ ក្នុង វិស័យដែលខ្លួនគ្រប់គ្រង ទៅក្រសួងផែនការ ។ ដោយឡែកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើ កញ្ចប់ថវិកាជំពូក ៥០ និងសេចក្ដីវាយតំលៃអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ទៅក្រសួងផែនការ ។

www.pheakdeylaw.com

មាត្រា ២៧ .-

ក្នុងខែសីហា-កញ្ញា ក្រសួងផែនការត្រូវពិនិត្យ វាយតំលៃ កំណត់ចំណាត់ថ្នាក់អាទិភាព ឲ្យចំពោះគម្រោងកម្មវិធីវិនិយោគសាធារណៈរបស់គ្រប់ក្រសួង-ស្ថាប័ន ដូចក្នុងមាត្រា ៥ មាត្រា១៤ ត្រូវចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ និងត្រូវដឹកនាំការប្រជុំអន្តរក្រសួង-ស្ថាប័ន ដើម្បីធ្វើការកែតម្រូវសេចក្តីព្រាង កម្មវិធីវិនិយោគសាធារណៈនោះ រួចផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើសមាហរណកម្ម និងបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយនិងជូនសេចក្តីព្រាងកម្មវិធីវិនិយោគសាធា-រណៈ មកគណៈរដ្ឋមន្ត្រី ពិនិត្យ អនុម័ត ។

មាត្រា ២៨ .-

ក្នុងខែតុលា គណៈរដ្ឋមន្ត្រីធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ។

## ជំពូក ទី៦
## អវសានប្បញ្ញត្តិ

មាត្រា២៩ .-

អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៩៨ សេចក្តីសំរេចលេខ ៣១ សសរ ចុះថ្ងៃទី០៥ ខែកញ្ញាឆ្នាំ១៩៩៧ សារាចរអន្តរស្ថាប័នលេខ ១៩៨២/៩៩ ស.រ.ប ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ១៩៩៩ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣០ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងប្រធានស្ថាប័នទាំងអស់ ត្រូវអនុវត្ត អនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងផែនការ

ហត្ថលេខា

**ឆាយ ថន**

★★★

www.pheakdeylaw.com